ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខៈ......១៩......ស.ល.ខ

# សារលិខិតជូនពរ
## សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម
## ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

**សម្តេចអគ្គមហាធម្មពោធិសាលប្រធានព្រឹទ្ធសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

នៅក្នុងឱកាសដ៏នក្ខត្តឫក្សប្រសើរថ្លៃថ្លា ប្រកបដោយមនោសញ្ចេតនាសោមនស្សរីករាយនៃខួបកំណើត គម្រប់ ៧៨ឆ្នាំ ឈានចូល ៧៩ឆ្នាំ របស់សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃទីស្តីការគណៈរដ្ឋមន្ត្រី ខ្ញុំនិងភរិយាសូមសម្តែង នូវសេចក្តីអំណរសាទរឥតឧបមា ប្រកបដោយកតញ្ញូកតវេទិតាធម៌ និងក្នុងមនោសញ្ចេតនា ប្រកបដោយសេចក្តីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត សូមចូលរួមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីវឌ្ឍនា វិបុលសុខ មហាប្រសើរគ្រប់យ៉ាងជូនចំពោះសម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងសូមសម្តេចទទួលបាននូវសុខភាពល្អបរិបូណ៌ បញ្ញាញាណភ្លឺថ្លា កាយពលរឹងមាំ ជន្មាយុយឺនយូរតរៀងទៅ។

យើងខ្ញុំទាំងអស់គ្នាតែងតែនឹកឃើញ និងចងចាំជានិច្ចមិនអាចបំភ្លេចបាននូវគុណូបការៈដ៏ខ្ពង់ខ្ពស់របស់សម្តេចប្រធាន ដែលតែងតែបានយកអស់កម្លាំងកាយ ប្រាជ្ញា ស្មារតី និងបទពិសោធមកបម្រើផលប្រយោជន៍ជូនជាតិមាតុភូមិនិងប្រជាជន តាមរយៈការចូលរួមចំណែកយ៉ាងធំធេងក្នុងការដំណើរការពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា ការគោរពសិទ្ធិមនុស្ស ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ការកែទម្រង់រដ្ឋស៊ីជម្រៅលើគ្រប់វិស័យ សំដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងធ្វើឱ្យមាតុភូមិកម្ពុជាជាទីស្នេហាមានការអភិវឌ្ឍរីកចំរើនជឿនលឿនឆាប់រហ័សនាពេលកន្លងមក។

ឆ្លៀតក្នុងឱកាសដ៏ជ័យមង្គលវិសេសវិសាលនេះផងដែរ យើងខ្ញុំទាំងអស់គ្នា សូមលើកហត្ថប្រណម្យបួងសួង ដល់អស់ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គុណបុណ្យព្រះរតនត្រ័យកែវទាំងបី តេជៈបារមីព្រះឥន្ទ ព្រះព្រហ្ម ព្រះអង្គចេក ព្រះអង្គចម វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមព្រះអង្គតាមជួយថែរក្សាការពារ និងប្រោះព្រំសព្ទសាធុការពរជ័យគ្រប់ប្រការចំពោះសម្តេចប្រធាន និងបុត្រា បុត្រី ចៅប្រុស ចៅស្រីជាទីស្រឡាញ់ សូមបានសមប្រកបដោយនូវពុទ្ធពរទាំងបួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមសម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ និងភក្តីភាពដ៏ស្មោះស្ម័គ្របំផុតពីយើងខ្ញុំទាំងអស់គ្នា ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១១
**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃទីស្តីការគណៈរដ្ឋមន្ត្រី**
**ឧបនាយករដ្ឋមន្ត្រី**

**សុខ អាន**